Operating in Brilliance

លេខ: GTPR-2408-001

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ភាពមិនច្បាស់លាស់ជាសារវន្តលើនិរន្តភាពនៃរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី២ ឆ្នាំ២០២៤

**ក្រុមហ៊ុន ហ្គោលដេន ទ្រី** (“ក្រុមហ៊ុន”) ដែលជាក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលបៃតងដំបូងគេនៅ កម្ពុជា និង បាន ចុះបញ្ជីលើទីផ្សារ មូលបត្រកម្ពុជា (ផមក) កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និង សាធារណជនមេត្តាជ្រាបថា៖

ដូចបានផ្សព្វផ្សាយក្នុងរបាយការណ៍ក្រុមហ៊ុនសម្រាប់ត្រីមាសទី២ ឆ្នាំ២០២៤ តាមរយៈគេហទំព័រផ្លូវការរបស់ផ្សារមូលបត្រកម្ពុជា (ផមក) នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រានៃត្រីមាសទី២ ឆ្នាំ២០២៤ របស់ក្រុមហ៊ុនមានការបង្ហាញពីសវនករឯករាជ្យ ចំពោះការមិនអាចកំណត់ភាពសមស្របនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនដោយផ្អែកលើមូលដ្ឋាននៃនិរន្តរភាព។

ម្ចាស់មូលបត្របំណុល វិនិយោគិន និងសាធារណជន គួរពិនិត្យមើលព័ត៌មានបន្ថែមដែលបានផ្សព្វផ្សាយក្នុងរបាយការណ៍ក្រុមហ៊ុនសម្រាប់ត្រីមាសទី២ ឆ្នាំ២០២៤ ដូចខាងក្រោម៖

១. របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រានៃត្រីមាសទី២ ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធក្នុងរបាយការណត្រីមាសទី ២ របស់ក្រុមហ៊ុន

- របាយការណ៍នៃការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ជូនចំពោះភាគហ៊ុនិករបស់ក្រុមហ៊ុន ហ្គោលដេន ទ្រី (ទំព័រទី២)
- កំណត់សម្គាល់ទី៣.២. និរន្តរភាព (ទំព័រទី១៣)

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់មូលបត្របំណុល វិនិយោគិន និងសាធារណជន មេត្តាទទួលជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃ ចន្ទ ១៥ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹង ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤

ហ្គោលដេន ទ្រី
GOLDEN TREE
Co., Ltd.

**ក្រុមហ៊ុន ហ្គោលដេន ទ្រី**

Excellence In Design
For Greater Efficiencies
Edge

Plot A, Stree 169, Sangkat
Veal vong, Khan 7 Makara,
Phnom Penh, Cambodia

enquiry@goldentree.com.kh
www.goldentree.com.kh
(855) 87 888 636 / 99 499 457